**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ១០ **អយក.**សបសណ

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង ថ្នាក់បរិញ្ញាបត្រទៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិនក្នុងឆ្នាំសិក្សា២០១៦-២០១៧

**យោង**: លិខិតលេខ១១៩៦អស២.កបទ.សអ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ក្រសួងអប់រំ យុវជន និងកីឡា**

សូមជូនដំណឹងថាក្នុងឆ្នាំ២០១៦នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនបានផ្តល់អាហារូបករណ៍ចំនួន ៤៥ កន្លែង ដល់សិស្ស-និស្សិត-មន្ត្រីរាជការ-បុគ្គលិកអង្គការ-ក្រុមហ៊ុននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រនៅសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ។ សោហ៊ុយធ្វើដំណើរទៅ-មក ជាបន្ទុករបស់សាមីជន ឯការចំណាយផ្សេងៗលើការស្នាក់នៅ ការសិក្សា និងប្រាក់អាហារូបករណ៍ជាបន្ទុករបស់រដ្ឋាភិបាលចិន ។

**I-មុខវិជ្ជាសម្រាប់សិក្សាមាន**:

-វិទ្យាសាស្ត្រ វិស្វកម្ម សេដ្ឋកិច្ច ការគ្រប់គ្រងពាណិជ្ជកម្ម វេជ្ជសាស្ត្រ ព័ត៌មានវិទ្យា ។ល។

**II-លក្ខខណ្ឌនៃការដាក់ពាក្យ**

**ក-ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

បេក្ខជនទាំងពីរភេទត្រូវ:

-មានសញ្ជាតិខ្មែរ

-មានសញ្ញាបត្របរិញ្ញាបត្រ (Bachelor)

-មានអាយុយ៉ាងច្រើន ៣៥ ឆ្នាំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

-មានចំណេះដឹងភាសាអង់គ្លេសជ្រៅជ្រះព្រោះការសិក្សាប្រព្រឹត្តទៅជាភាសាអង់គ្លេស

-មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

**ខ-ថ្នាក់បរិញ្ញាបត្រ**

បេក្ខជនទាំងពីរភេទត្រូវ:

-មានសញ្ជាតិខ្មែរ

-មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ

-មានអាយុលើសពី ១៨ឆ្នាំ

-មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា

## III-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ

ពាក្យសុំប្រឡងនឹងទទួលចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី**០៧** ខែ**មីនា** ឆ្នាំ**២០១៦** វេលាម៉ោង ១៦ម៉០០ នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ស្ថិតនៅអគារលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន (ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាចម្ងាយ៥០ម៉ែត្រ)។

## IV-កាលបរិច្ឆេទប្រឡង

ប្រឡងនៅថ្ងៃទី **១៣** ខែ **មីនា** ឆ្នាំ **២០១៦** ។ មណ្ឌលប្រឡងនឹងជម្រាបជូនពេលក្រោយ ។

## V-វិញ្ញាសាប្រឡង

**សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

| | | |
|---|---|---|
| -វប្បធម៌ទូទៅ | រយៈពេល | ០១ម៉ោង ៣០នាទី |
| -ភាសាអង់គ្លេស | រយៈពេល | ០១ម៉ោង ៣០នាទី |

**សម្រាប់ថ្នាក់បរិញ្ញាបត្រ**

| | | |
|---|---|---|
| -គណិតវិទ្យា | រយៈពេល | ០១ម៉ោង ៣០នាទី |
| -ភាសាអង់គ្លេស | រយៈពេល | ០១ម៉ោង ៣០នាទី |

## VI-សំណុំឯកសារត្រូវបំពេញ និងភ្ជាប់មកជាមួយមាន:

| | |
|---|---|
| ១-បង្កាន់ដៃទទួលពាក្យ | ០១ច្បាប់"មានគំរូ" |
| ២-ពាក្យសុំអាហារូបករណ៍ | ០១ច្បាប់"មានគំរូ" |
| ៣-ជីវប្រវត្តិសង្ខេប | ០១ច្បាប់"មានគំរូ" |
| ៤-កិច្ចសន្យា | ០១ច្បាប់"មានគំរូ" |
| ៥-រូបថត ៤ គុណ ៦ ០៤សន្លឹក | (ពណ៌ធម្មជាតិទើបថតថ្មី) |

៦-សញ្ញាបត្របរិញ្ញាបត្រ(ច្បាប់ថតចម្លង ០១ ច្បាប់ ) សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

៧-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ (ច្បាប់ថតចម្លង ០១ច្បាប់ )សូមភ្ជាប់ច្បាប់ដើមមកជាមួយដើម្បីផ្ទៀងផ្ទាត់សម្រាប់ថ្នាក់បរិញ្ញាបត្រ ។

៨-លិខិតបញ្ជាក់ការសិក្សាពីគ្រឹះស្ថានសិក្សាចំពោះនិស្សិតកំពុងសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សានានា។

៩-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង " ចំពោះបេក្ខជន ជាមន្ត្រីរាជការ"

១០-វិញ្ញាបនបត្រពិនិត្យកាយសម្បទា " ០២សន្លឹក " បំពេញក្រោយពេលដែលសាមីជនត្រូវបានប្រឡងជ្រើសរើសរួច។

ផ្អែកលើលទ្ធផលប្រឡងក្រសួងអប់រំ យុវជន និងកីឡានឹងជ្រើសរើសនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន **២០**នាក់ និងថ្នាក់បរិញ្ញាបត្រចំនួន**២៥**នាក់ ដើម្បីបញ្ជូនទៅស្ថានទូតចិនមានវិធានការបន្ត ។

ចំពោះព័ត៌មានលម្អិតបន្ថែមទៀតសូមអញ្ជើញទាក់ទងជាមួយការិយាល័យអាហារូបករណ៍ និងកម្មសិក្សាតាមអាស័យដ្ឋានខាងលើ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

យក់ ឌ៉យ

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា
"ដើម្បីជូនជ្រាបជាព័ត៌មាន "
-គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
-គ្រប់គ្រឹះស្ថានឧត្តមសិក្សា
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត-ក្រុង
"ដើម្បីជួយផ្សព្វផ្សាយ និងឧទ្ទេសនាម "
-កាលប្បវត្តិ ឯកសារ នា.ទអ